ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និយោជិត សាស្ត្រាចារ្យ និស្សិត កម្មករនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្តទាំងអស់ សូមសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះសេចក្តីថ្លែងការណ៍ពិសេសរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៤ ធ្វើការថ្កោលទោសយ៉ាងដាច់ខាតចំពោះលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ ដែលបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ **ព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** តាមរយៈសារលិខិតរបស់ខ្លួនចុះថ្ងៃទី០២ ខែ មេសា ឆ្នាំ២០១៤ តបទៅនឹងព្រះរាជសាររបស់ **ព្រះករុណាព្រះមហាក្សត្រ** នាឱកាសបើកបវេសនកាលនៃរដ្ឋសភានាសម័យប្រជុំលើកទី២នីតិកាលទី៥កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤កន្លងទៅនេះ។

ទង្វើអគតិនិងព្រហើនកោងកាចរបស់លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ ដែលបានប្រមាថមាក់ងាយដល់ព្រះកិត្តិយស និងព្រះកិត្តិនាមរបស់ **ព្រះមហាក្សត្រ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជាជាតិ និងប្រជារាស្ត្រខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា បានបង្ហាញឱ្យឃើញយ៉ាងប្រត្យក្សពីការបំពាន និងធ្វើឱ្យប៉ះពាល់ដល់ស្ថាប័នកំពូលរបស់ជាតិ ព្រះរាជបល្ល័ង្ក និងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាដែលកើតចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋតាមរយៈការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងជាសម្ងាត់ហើយមានភាពរលូន គ្មានអំពើហឹង្សាប្រកបដោយសន្តិភាព ត្រឹមត្រូវ និងយុត្តិធម៌។

យើងខ្ញុំទាំងអស់គ្នា សូមប្រកាសដាច់អហង្ការ ថ្កោលទោសចំពោះទង្វើរបស់ លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ ដែលមានចេតនាបំភ័ន្តដល់សាធារណមតិជាតិ និងអន្តរជាតិអំពីភាពស្របច្បាប់នៃរដ្ឋសភា និងរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នេះ និងសូមគាំទ្រឥតងាករេចំពោះវិធានការទាំងឡាយរបស់រាជរដ្ឋាភិបាល ដើម្បីការពាររដ្ឋធម្មនុញ្ញ រាជបល្ល័ង្ក ផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់ប្រទេសជាតិ ប្រជាជនកម្ពុជា និងមាតុភូមិកម្ពុជាដ៏រុងរឿង ដោយឈរលើមូលដ្ឋាននៃការពង្រឹងនីតិរដ្ឋ និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។៤

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៤

**ថ្នាក់ដឹកនាំ មន្ត្រីរាជការ និយោជិត សាស្ត្រាចារ្យ និស្សិត**
**កម្មករ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**